**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តមណ្ឌលគិរី**

-សំណុំរឿងព្រហ្មទណ្ឌលេខ២៨៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខ២៤៤ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១
-សាលក្រមលេខ ២១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២

# សាលក្រម

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

បានបើកសវនាការជាសាធារណៈនាថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ដែលមានសមាសភាពជំនុំជម្រះដូចតទៅ:

### ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តមណ្ឌលគិរី

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តមណ្ឌលគិរី

### មេធាវី

លោក [redacted] **ខេម៉ា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ

លោក [redacted] **សិទ្ធហេង** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ឌី

លោក [redacted] **ដារិទ្ធ** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុផល

លោក [redacted] **ទាសនា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ណាខៃ និង ឈ្មោះ [redacted] ចន្ទារី ។

-ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ:២៨៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] **ណាខៃ** ភេទប្រុស កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៩ ជាទីតិជន ជនជាតិខ្មែរ មុខរបរ មន្ត្រីយោធា ទីកន្លែងកំណើត[redacted] ទីលំនៅបច្ចុប្បន្ននៅ[redacted] ឪពុកឈ្មោះ [redacted] ចន (ស) ម្តាយឈ្មោះ[redacted]ស៊ី (ស) ប្រពន្ធឈ្មោះ [redacted] សៅរី មានកូន ០១នាក់ ទោសពីមុនគ្មាន។

២. ឈ្មោះ[redacted] **ចន្ទារី** ភេទប្រុស អាយុ ៥១ឆ្នាំ ជាទីតិជន ជនជាតិខ្មែរ មុខរបរ មន្ត្រីយោធា ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ននៅ[redacted] ឪពុកឈ្មោះ [redacted] សន (រ) ម្តាយឈ្មោះ[redacted] សេង (ស) ប្រពន្ធឈ្មោះ [redacted] គីមហ៊ួយ មានកូន ០២នាក់ ទោសពីមុនគ្មាន។



Scanned with CamScanner

៣.ឈ្មោះ [redacted] ញៀក ភេទប្រុស កើតថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៨ ជនជាតិពូនង មុខរបរ មន្ត្រីយោធា ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] ឡឹក (រ) ម្តាយឈ្មោះ [redacted] ហិន (រ) ប្រពន្ធឈ្មោះ [redacted] សារី មានកូន ០២នាក់ ទោសពីមុនគ្មាន ។

៤. ឈ្មោះ [redacted] **ភារ័ត្ន** ភេទប្រុស អាយុ ៥២ឆ្នាំ ជាទីតិជន ជនជាតិខ្មែរ មុខរបរ វរៈសេនាតូចការពារព្រំដែនគោកលេខ ៦២១ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] ឈានអេង (ស) ម្តាយឈ្មោះ [redacted] គីមអ៊ាន (ស) ប្រពន្ធឈ្មោះ [redacted] សុផល មានកូន ០៤នាក់ ទោសពីមុនគ្មាន។

៥. ឈ្មោះ [redacted] **វណ្ណៈ** ហៅ **សុផល** ភេទប្រុស អាយុ ៤៩ឆ្នាំ ជាទីតិជន ជនជាតិខ្មែរ មុខរបរ នគរបាល ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] យ៉ែម (ស) ម្តាយឈ្មោះ [redacted] មុំ (ស) ប្រពន្ធឈ្មោះ [redacted] ហា មានកូន ០២នាក់ ទោសពីមុនគ្មាន។

៦. ឈ្មោះ [redacted] **ចាន់ឌី** ភេទប្រុស អាយុ ៤១ឆ្នាំ ជាទីតិជន ជនជាតិខ្មែរ មុខរបរ មន្ត្រីយោធា ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] លាងអេង (ស) ម្តាយឈ្មោះ [redacted] ជុំស្រាង (ស) ប្រពន្ធឈ្មោះ [redacted] សុផាន់នី មានកូន ០២នាក់ ទោសពីមុនគ្មាន។

៧. ឈ្មោះ [redacted] **សុខឡេង** ហៅ **ម៉ាប់** ភេទប្រុស កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៦៧ ជាទីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី៨ ជនជាតិខ្មែរ មុខរបរ នគរបាល ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] ឡេង (ស) ម្តាយឈ្មោះ [redacted] សន (ស) ប្រពន្ធឈ្មោះ [redacted] សារឿន មានកូន ០៣នាក់ ទោសពីមុនគ្មាន។

៨. ឈ្មោះ [redacted] **សុផល** ភេទប្រុស អាយុ ៥១ឆ្នាំ ជាទីតិជន ជនជាតិខ្មែរ មុខរបរ មន្ត្រីយោធា ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] ផាន់ (ស) ម្តាយឈ្មោះ [redacted] អាត (រ) ប្រពន្ធឈ្មោះ [redacted] សម្រស់ មានកូន ០៧នាក់ ទោសពីមុនគ្មាន ឃាត់ខ្លួនថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ។

ជាប់ចោទពីបទ: **ធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ និងដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ** តាមបញ្ញត្តិមាត្រា ១០០ នៃច្បាប់ស្តីព្រៃឈើ ប្រព្រឹត្តនៅត្រង់ចំណុច អូរហ៊ុច ស្ថិតនៅភូមិអូរអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២១ ។



Scanned with CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីអំឡុងខែឧសភា ខែមិថុនា ឆ្នាំ២០២១ នៅចំណុចអូរហ៊ុច ក្នុងភូមិអូរអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី មានករណីបទល្មើសធនធានធម្មជាតិ ករណីនាំចេញផល អនុផលព្រៃឈើ ដែលគ្មានអាជ្ញាប័ណ្ណ ករណីធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតផ្ទាល់ឬដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ និងករណីចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយលបលាក់បានកើតឡើង ប្រព្រឹត្តដោយជនជាប់ចោទជាជនជាតិវៀតណាម និងជនជាតិខ្មែរ ។ ជនជាប់ចោទឈ្មោះ [redacted] ណាខៃ ជាមេបញ្ជាការអនុសេនាធំលេខ២ ឈ្មោះ [redacted] ញ៉ែក ជាមេបញ្ជាការរង អនុសេនាធំលេខ២ ឈ្មោះ [redacted] ចាន់នី ជាមេបញ្ជាការរង អនុសេនាធំលេខ២ ឈ្មោះ [redacted] ចន្ធារី ជាមេបញ្ជាការអនុសេនាតូចលេខ២ ឈ្មោះ [redacted] សុផល ជាជំនួយការគ្រឿងចក្ររបស់កងឯកភាពស្ថាបនាផ្តល់លេខ ៧១៦ បញ្ជាការដ្ឋានវិស្វកម្មអគ្គបញ្ជាការ ឈ្មោះ [redacted] ភារ័ត្ន ជានាយប៉ុស្តិ៍នគរបាលការពារព្រំដែនអូរហ៊ុច ឈ្មោះ [redacted] វណ្ណៈ ជានាយរងប៉ុស្តិ៍នគរបាលការពារព្រំដែនគោកអូរហ៊ុច និងឈ្មោះ [redacted] សុខឡេង ជានាយរងប៉ុស្តិ៍នគរបាលការពារព្រំដែនគោកអូរហ៊ុច បានទទួលប្រាក់ពីជនជាតិវៀតណាមឈ្មោះ [redacted] ភេទប្រុស និងឈ្មោះ [redacted] ភេទប្រុស ជាថ្នូរនិងអនុញ្ញាតដោយផ្ទាល់ និងដោយប្រយោលឱ្យឈ្មោះ [redacted] និងឈ្មោះ ជី នាំបក្ខពួក និងត្រាក់ទ័រចូលមកកាប់ឈើ និងដឹកឆ្លងផ្លូវក្រវ៉ាត់ព្រំដែនត្រង់ចំណុចបង្គោលព្រំដែនលេខ៦០/៣៧ (១) ក្បែរបញ្ជាការដ្ឋានអនុសេនាតូចលេខ២ និងក្បែរប៉ុស្តិ៍នគរបាលការពារព្រំដែនអូរហ៊ុច ឆ្លងអូរចូលប្រទេសវៀតណាម ។ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ តំណាងអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី បានដឹកនាំក្រុមការងារចម្រុះចុះទៅបង្ក្រាបដកហូតបានឈើមូល ឈើអារប្រភេទលេខ១ (ស្រឡៅ សុក្រម ) ចំនួន ២៦៥២ កំណាត់ ត្រាក់ទ័រ ០២គ្រឿង ម៉ូតូ ០២គ្រឿង និងរណារយន្តលេខ០៣៨ ចំនួន ០១គ្រឿង ។

-បានឃើញ: ដីកាដំណោះស្រាយលេខ: ១២២៦/២១ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគិរី ។

-បានឃើញ: សំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះលេខ: ២៤៤ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តមណ្ឌលគិរី។

-បានឃើញ: ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តមណ្ឌលគិរី ។

-បានឃើញ: ដីកាចាត់សម្រេចដាក់រឿងជំនុំជម្រះលេខ: ១៤៩៤/២១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តមណ្ឌលគិរី ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ណាខៃ** បានឆ្លើយថា៖ ខ្លួនមានតួនាទីជាមេបញ្ជាការអនុសេនាធំលេខ២ ប្រចាំស្រុកកែវសីមា ខេត្តមណ្ឌលគិរី នៅតាមបន្ទាត់ព្រំដែនគោកកម្ពុជា-វៀតណាម (ឡាប៉ាខេ) ឃុំស្រែខ្ទុម ស្រុកកែវសីមា តំបន់អូរហ៊ុច។កាលពីខែមេសាឆ្នាំ២០២១ មានកូនចៅឈ្មោះ [redacted] ញ៉ែក បានមកឆ្លងយោបល់ថាសុំឱ្យវៀតណាម



Scanned with CamScanner

លួចចូលដឹកឈើមួយយប់ ហើយខ្លួនតបវិញថា ខ្លួនមិនមែនកាន់នៅហ្នឹងកន្លែងទេ មើលខ្លួនឯងទៅ មិនដឹងទេ ។ ក្រោយមកឈ្មោះ[redacted]ញៀក បានយកលុយឱ្យខ្លួនចំនួន ៦៥លានដុង ប្រហែល២ពាន់ដុល្លារ ។ កាលសុំខ្លួន គឺសុំតែមួយយប់ទេ ក្រៅពីនោះខ្លួនមិនដឹងទេ ពេលសមត្ថកិច្ចចុះប្រតិបត្តិការបង្រ្កាបក្នុងអំឡុងខែមិថុនា ឆ្នាំ២០២១ ដឹកនាំដោយលោក ព្រះរាជអាជ្ញារង គឺខ្លួននៅជាប់ចត្តាឡីស័ក ហើយខ្លួនបានផ្ទេរសិទ្ធិទៅឱ្យឈ្មោះ [redacted] សុផាត ខ្លួនគ្រាន់តែទទួលរបាយការណ៍ពីកូនចៅ ។ កាលពីខែប្រាំ,ប្រាំមួយ ខ្លួនទៅពិនិត្យតាមព្រំដែន ពុំមានឃើញអ្នកកាប់ឈើទេ ខ្លួនទទួលខុសត្រូវ តាមបន្ទាត់ព្រំដែនពីឡាប៉ាខេ ទៅដល់ស្នួល ។ ហើយខ្លួនក៏មិនបានបញ្ជាឱ្យកូនចៅរារាំងសមត្ថកិច្ចទេ ។

-ជនជាប់ចោទឈ្មោះ [redacted] ចន្ធារី បានឆ្លើយថា៖ ខ្លួនជាមេបញ្ជាការកងអនុសេនាតូចលេខ២ នៅក្នុងកងអនុសេនាតូចលេខ២ ស្ថិតនៅក្នុងសីករងខេត្តមណ្ឌលគិរី ។ កាលពីថ្ងៃកើតហេតុមានឈ្មោះ [redacted]ញៀក គាត់គ្រប់គ្រងលើខ្លួន មកសុំចេញឈើមួយយប់ ហើយខ្លួនឆ្លើយថា មេយល់ព្រមអត់ ឈ្មោះ [redacted] ញៀក បានឆ្លើយថា មេយល់ព្រមអស់ហើយ ខ្លួនក៏បានព្រមតាមហ្នឹងដែរ ។ ខ្លួនបានទទួលប្រាក់ចំនួន ៤០លានដុង ពីឈ្មោះ [redacted] ញៀក ពេលបានប្រាក់ខ្លួនបានទិញសម្ភារៈដាក់កន្លែងធ្វើការងារអស់ចំនួន ១០លានដុង និងបានឱ្យកូនចៅម្នាក់ៗចំនួន ២លានដុង មានឈ្មោះ [redacted]សុខហេង,ឈ្មោះ[redacted]ប៊ុនី,ឈ្មោះ [redacted] ផន និងឈ្មោះ [redacted]អ៊ីណារ ។ ខ្លួនមិនដឹងថាគេប្រើមធ្យោបាយអ្វីក្នុងការដឹកឈើនោះទេ ហើយដែលគេកាប់ឈើជាច្រើនខ្លួនពុំបានដឹងទេ ខ្លួនទទួលប្រាក់ពីឈ្មោះ [redacted] ញៀក ចំនួន ៤០លានដុងទេ ចំណែកឯខាងទាហ៊ានខ្លួនទទួលលុយសរុបពីជនជាតិវៀតណាមចំនួន ១២០ លានដុង ។ ខ្លួនមិនដឹងថាអ្នកណានាំវៀតណាមចូលមកកាប់ឈើនោះទេ ចំណែកអ្នកទទួលលុយពីជនជាតិវៀតណាម គឺឈ្មោះ [redacted] ញៀក ព្រោះខ្លួនឃើញ នៅជាមួយគ្នា ។ ខ្លួនពុំបានធ្វើសកម្មភាពសម្រួលក្នុងការដឹកឈើចេញទេ កន្លែងដឹកឈើមិនឆ្ងាយពីកន្លែងខ្លួនប៉ុន្មានទេ ហើយវៀតណាមដែលដឹកឈើចេញនោះមានឈ្មោះ ប៊ិច គឺសុំតែមួយយប់ទេ ក្រៅពីនេះខ្លួនពុំបានដឹងទេ ។ ក្រោយមកខ្លួនបានសុំមេបញ្ជាការឈ្មោះ[redacted] ណារ៉ៃ ឱ្យវៀតណាមចូលកាប់ឈើ តែមេបញ្ជាការថាមិនបានទេ ខ្លួនក៏ឈប់តែម្តង ។ ខ្លួនស្គាល់ឈ្មោះ ប៊ិច ជាមួយឈ្មោះ[redacted] ញៀក ។

-ជនជាប់ចោទឈ្មោះ[redacted] ញៀក បានឆ្លើយថា៖ ក្នុងអំឡុងចុងខែមីនា ឆ្នាំ២០២១ ជនជាតិវៀតណាមឈ្មោះ ប៊ិច បានមកទំនាក់ទំនងខ្លួននៅប៉ុស្តិ៍អូរហ៊ុច ពេលខ្លួនទៅដល់ប៉ុស្តិ៍អូរហ៊ុចឃើញមានឈ្មោះ[redacted]ចន្ធារី បាននៅជាមួយវៀតណាមនោះ ហើយបាននិយាយថា សុំចេញឈើតែមួយយប់ទេ ដោយវៀតណាមនោះឱ្យលុយចំនួន ១២០ លានដុង ខ្លួនក៏បានទូរស័ព្ទទៅមេ ([redacted] ណារ៉ៃ)អំពីរឿងខាងលើគាត់ក៏បានឯកភាព ។ ខ្លួនក៏បានបោះដៃ ប្រាប់ទៅជនជាតិវៀតណាមឱ្យចូលកាប់ឈើ ហើយប្រាក់ដែលខ្លួនបានទទួលពីជនជាតិវៀតណាមឈ្មោះ ប៊ិច ចំនួន ១២០ លានដុង ដោយផ្ទាល់ ហើយយកប្រាក់នោះមកចែកគ្នានៅប៉ុស្តិ៍អូរហ៊ុច ដោយចែកគ្នាចំនួនបីនាក់ គឺឈ្មោះ[redacted] ចន្ធារី បានចំនួន ៤០ លានដុង មេបាន ៦៥លានដុង([redacted] ណារ៉ៃ) និងខ្លួនទទួលបាន១៥លានដុង ។ខ្លួនមិនដឹងថាអ្នកណាជាអ្នកនាំជនជាតិវៀតណាមឈ្មោះ ប៊ិច ឆ្លងមកទេនៅពេលខ្លួនទៅដល់ប៉ុស្តិ៍អូរហ៊ុចឃើញជនជាតិវៀតណាមតែម្នាក់ឈ្មោះ ប៊ិច ដែលនៅជាមួយឈ្មោះ [redacted] ចន្ធារី។ ចំពោះមន្ត្រីយោធាវិស្វកម្ម និងនគរបាលប៉ុស្តិ៍ព្រំដែននៅអូរហ៊ុច ខ្លួនមិនដឹងទេ ។

-ជនជាប់ចោទឈ្មោះ [redacted] **ភារ័ត្ន** បានឆ្លើយថា៖ ខ្លួនមានតួនាទីជានាយប៉ុស្តិ៍នគរបាលព្រំដែនគោកអូរហ៊ុច។ ពាក់ព័ន្ធនឹងការអូសឈើឆ្លងព្រំដែនទៅប្រទេសវៀតណាម គឺមានការត្រូវរ៉ូវគ្នារវាងប៉ុស្តិ៍ទាំងពីរ (ប៉ុស្តិ៍នគរបាលការពារព្រំដែន និងប៉ុស្តិ៍យោធាការពារព្រំដែន) រួចហើយ បន្ទាប់មកខាងវៀតណាមឈ្មោះ ប៊ិច មកសួរនាំខ្លួន សុំឈើចេញ ហើយខ្លួនថា ខាងយោធាអនុញ្ញាតឬនៅ គាត់ថាព្រមហើយ ខ្លួនក៏អនុញ្ញាត ។ ខ្លួនបានទទួលប្រាក់ពីជនជាតិវៀតណាមចំនួន ១០០លានដុង ហើយចែកឱ្យរងចំនួនពីរនាក់ដោយម្នាក់ៗបាន ២០លានដុង (ខ្លួនបានប្រគល់លុយទៅឱ្យឈ្មោះ [redacted] វណ្ណៈ ចំនួន ២០លានដុង និងឈ្មោះ [redacted] សុខឡេង ចំនួន ២០លានដុង) ហើយមន្ត្រីខ្លួនពីរនាក់ចំនួន ២លានដុង ខ្លួនបានទិញស្ងូឡាដាក់ប៉ុស្តិ៍សម្រាប់យាមអស់ចំនួន ២០លានដុង ។ ខ្លួនទទួលបានលុយពីវៀតណាមចំនួន ១០០លានដុង នៅចុងខែមេសា ថាសុំចេញឡានមួយ ក្រៅពីនោះខ្លួនពុំបានដឹងទេ ។ បើមិនត្រូវរ៉ូវគ្នាចេញមិនបានទេ មានយោធា នគរបាល និងវិស្វកម្ម ។

-ជនជាប់ចោទឈ្មោះ [redacted] **វណ្ណៈ** ហៅ **សុផល** បានឆ្លើយថា៖ ខ្លួនមានតួនាទីជានាយរងប៉ុស្តិ៍ការពារព្រំដែនអូរហ៊ុច ខ្លួនមានជម្ងឺសរសៃឈាម និងបេះដូង ខ្លួនពុំបានដឹងវៀតណាមចេញចូលទេ ។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឈ្មោះ [redacted] ភារ័ត្ន ដែលជានាយប៉ុស្តិ៍បានប្រគល់ប្រាក់ឱ្យខ្លួនចំនួន ៤០លានដុង ទុកចែកគ្នាជាមួយឈ្មោះ [redacted] សុខឡេង ចំនួន ២០លានដុង ដែលជានាយរងប៉ុស្តិ៍ដូចគ្នា ដោយមិនបានប្រាប់ថាជាលុយអ្វីនោះទេ ។ ហើយខ្លួនក៏ពុំបានសួរថាលុយអ្វីដែរ ខ្លួនក៏បានយកលុយនេះមកទិញថ្នាំព្យាបាលជម្ងឺ ។ ចំពោះលុយទទួលបានពីឈ្មោះ [redacted] ភារ័ត្ន ខ្លួនពុំបានសួរនាំគាត់ថាលុយអ្វីនោះទេ ពេលតំណាងអយ្យការចុះប្រតិបត្តិខ្លួននៅប៉ុស្តិ៍។ ពេលដែលប្រគល់ប្រាក់ចំនួន២០លានដុងឱ្យទៅឈ្មោះ [redacted] សុខឡេង រួច ឈ្មោះ [redacted] សុខឡេង ក៏ចេញដំណើរពីប៉ុស្តិ៍ទៅផ្ទះតែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] **ចាន់ធី** បានឆ្លើយថា៖ ខ្លួនមានតួនាទីជាមេបញ្ជាការរងអនុសេនាធំលេខ២ ទទួលបន្ទុកការពារគ្រឿងចក្រស្តាបនាផ្លូវខ្សែក្រវ៉ាត់ព្រំដែនគោក ចាប់ពីព្រំប្រទល់ខេត្តក្រចេះដល់ដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ។ ខ្លួនពុំដឹងថាវៀតណាមចូលមកកាប់ឈើនោះទេ គឺខ្លួនទទួលតែធ្វើការងារខាងវិស្វកម្មទេ ខ្លួនពុំដែលបានទទួលប្រាក់ពីជនជាតិវៀតណាមនោះទេ ។ ថ្ងៃកើតហេតុខ្លួនជាប់ចត្តាឡីស័ក ខ្លួនទទួលស្គាល់ថា ខ្លួនធ្លាប់ទទួលប្រាក់ចំនួន ៨លានដុង ហើយប្រគល់ទៅឱ្យឈ្មោះ [redacted] សុផល ចំនួន ៤លានដុង ដែលជាថ្នូរនឹងការចាប់ម៉ូតូដឹកឈើចំនួនពីរគ្រឿងចូលទៅប្រទេសវៀតណាម កាលពីចុងខែមីនា ឆ្នាំ២០២១។ ខ្លួនទទួលបានប្រាក់ចំនួន ៣លានដុង ពីម៉ូតូវៀតណាមដឹកឈើចំនួនពីរគ្រឿង ហើយបានប្រគល់លុយទៅឱ្យឈ្មោះ [redacted] សុផល ចំនួន ៤លានដុង ដោយពុំបានប្រាប់ឈ្មោះ [redacted] សុផល ថាលុយបានមកពីណានោះទេ គឺថាគេឱ្យចាយ។ សរុបខ្លួនទទួលប្រាក់បានចំនួន ៧លានដុង គឺយកពីអ្នកបើកបរម៉ូតូទទេ ខ្លួនចុះទៅមើលកម្លាំងធ្វើផ្លូវក្រវ៉ាត់ព្រំដែន ក្នុងមួយខែម្តង។

-ជនជាប់ចោទឈ្មោះ [redacted] **សុខឡេង** ហៅ **មាប់** បានឆ្លើយថា៖ ខ្លួនជានាយរងប៉ុស្តិ៍នគរបាលព្រំដែនគោកអូរហ៊ុច ដោយមានភារកិច្ចល្បាតតាមខ្សែបន្ទាត់ព្រំដែន ដោយមានមេប៉ុស្តិ៍ឈ្មោះ [redacted] ភារ័ត្ន ហើយខ្លួនពុំបានអនុញ្ញាតឱ្យជនជាតិវៀតណាមចូលមកកាប់ឈើនោះទេ ខ្លួនមិនដែលបានទទួលប្រាក់នោះទេ គឺខ្លួនមកនៅផ្ទះតាំងពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ គេរៀបចំប៉ុស្តិ៍ រហូតដល់ថ្ងៃទី១៦ មុនកើតហេតុ ខ្លួននៅធ្វើចត្តាឡីស័ក ។ ចំពោះខែបួន ខែប្រាំ ខ្លួន

ទៅកន្លែងយូរៗម្តង ព្រោះខ្លួនមានជម្ងឺទឹកនោមផ្អែម លើសឈាម ត្រឡប់មកផ្ទះវិញ ។ ខ្លួនសូមបញ្ជាក់ថា ខ្លួនពុំបានទទួលលុយទេ ព្រោះខ្លួនឈឺច្រើន ពុំដែលបាននៅកន្លែងជាប់លាប់ទេ ។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុផល** បានឆ្លើយថា៖ ខ្លួនជាជំនួយការគ្រឿងចក្ររបស់បញ្ជាការដ្ឋានវិស្វកម្មអគ្គបញ្ជាការ នៅចំណុចភូមិសាស្ត្រអូរហ៊ុច ។ ខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] ចាន់ឌី ចំនួន ៤លានដុង ខ្លួនមិនបានដឹងថាប្រាក់ដែលឈ្មោះ [redacted] ចាន់ឌី ប្រគល់ឱ្យខ្លួននេះបានមកពីក្រុមម៉ូតូដឹកឈើចូលប្រទេសវៀតណាមនោះទេ ហើយខ្លួនទទួលប្រាក់ពីឈ្មោះ [redacted] ចាន់ឌី ចំនួន១ដង នៅជិតផ្សារកែវសីមា ដោយគាត់ប្រាប់ថាលុយសម្រាប់បាយទឹក ។ ខ្លួនមិនបានដឹងថាអ្នកណាជាអ្នកបញ្ជាឱ្យបិទផ្លូវក្រុមសមត្ថកិច្ចដែលចុះប្រតិបត្តិការនៅយប់នោះទេ ។ កាលនៅបេអឹម ខ្លួនភ័យពេក ក៏បានឆ្លើយថា ទទួលប្រាក់ពីម៉ូតូដឹកឈើ ហើយទទួលបានចំនួនពីរដង ។ ខ្លួនទទួលលុយនៅពាក់កណ្តាលខែមីនា ទាក់ទងអ្នកបញ្ជាឱ្យបិទផ្លូវ ខ្លួនពុំដឹងអ្នកណាបញ្ជាទេ គឺគ្រាន់តែដឹងថា អ្នកនៅកន្លែងកើតហេតុជាអ្នកបិទ ខ្លួននៅស្នាក់ការប្រហែល១៣គីឡូម៉ែត្រ ហើយពេលនោះអាយគោមគ្មានសេវាមិនអាចបញ្ជាបាន ។

- សាក្សីឈ្មោះ [redacted] **សត្ថា** បានឆ្លើយថា៖នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ លោកប្រធានបានបញ្ជារកូនចៅឱ្យទៅប្រតិបត្តិការ ឃើញមានដានអាត្រាក់ទ័រ អូសឈើទៅចូលទឹកដីវៀតណាម ក្រោយមកកម្លាំងបានរាយការណ៍មកស្នាក់ការបរិស្ថានកែវសីមា រាយការណ៍បន្តមកលោកប្រធានមន្ទីរបរិស្ថាន បានស្នើសុំលោកព្រះរាជអាជ្ញា ។ ហើយដឹកនាំដោយលោកព្រះរាជអាជ្ញារង ទៅជិតដល់ស្នាក់ការអូរហ៊ុច ឃើញមានអាត្រាក់ទ័រចំនួនមួយគ្រឿង ហើយមានរថយន្តដឹកដីមួយគ្រឿងមានអ្នកបើកបរក្នុងភាពស្រវឹងស្រាមកបាំងផ្លូវអត់ឱ្យក្រុមការងារចូលទៅនោះទេ ។ ក្រោយមកក្រុមការងារបានឱ្យម៉ូតូទៅមុន ប៉ុស្តិ៍នគរបាលព្រំដែន និងយោធា មានចំងាយប្រហែលជា៦០០ម៉ែត្រ ពីកន្លែងកើតហេតុ ក្រោយមកកម្លាំងខ្លួនបានចាប់បានត្រង់សឺន័រ និងឈើជាច្រើនដុំ ហើយឈើមួយចំនួនបានយកមករក្សាទុកនៅស្នាក់ការបរិស្ថានខ្លះ និងមួយចំនួនដែលនៅសល់នៅកន្លែងកើតហេតុ។ ហើយពុំចាប់អ្នកបើកឡានមកបាំងផ្លូវទេ ព្រោះកន្លែងកើតហេតុនៅផ្សេងហើយជាកន្លែងកងវិស្វកម្មធ្វើការ ដោយសារតែខ្លាចបាត់បង់ទីតាំងកើតហេតុ និងបាត់បង់ភស្តុតាង ។ បន្ទាប់មកក៏បានធ្វើការស៊ើបអង្កេត ហើយបានកោះហៅអ្នកពាក់ព័ន្ធមកសួរនាំ រួចកសាងសំណុំរឿងមកតំណាងអយ្យការចាត់ការបន្ត។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលក្នុងសវនាការ ឃើញថាជនជាប់ចោទទាំង ០៨នាក់ ពិតជាបានទទួលប្រាក់ពីជនជនជាតិវៀតណាម ដោយផ្ទាល់ និងប្រយោល ដើម្បីឱ្យដឹកឈើចេញពីទឹកដីខ្មែរ ទៅប្រទេសវៀតណាម ពិតប្រាកដមែន ។ ហេតុនេះតំណាងអយ្យការប្តឹងចោទប្រកាន់ជនជាប់ចោទពី បទ **ធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ និងដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ** តាមបញ្ញត្តិមាត្រា ១០០ នៃច្បាប់ស្តីព្រៃឈើ ប្រព្រឹត្តនៅត្រង់ចំណុចអូរហ៊ុច ស្ថិតនៅភូមិអូរអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២១ ។ ប៉ុន្តែចំពោះចម្លើយដែលឈ្មោះ [redacted] សុខឡេង បានឆ្លើយដោះសារ ពុំទទួលប្រាក់នោះទេ ដើម្បីរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌ តំណាងអយ្យការពុំជឿជាក់នោះទេ

ព្រោះជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានយកលុយចំនួន ២០លានដុងឱ្យតាមបញ្ជាមេប៉ុស្តិ៍ឈ្មោះ [redacted] ភារ័ត្ន ដូចច្នេះ តំណាងអយ្យការប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខឡេង តាមច្បាប់។

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនពិតជាបានទទួលប្រាក់ពិតមែន ហើយឈ្មោះ [redacted] ណារ៉ែ បានទទួល៦៥លានដុង និងឈ្មោះ [redacted] ចន្ថារី ទទួលបាន ៤០លានដុង គឺទទួលយកមកដើម្បីកសាងស្នាក់ការ ធ្វើការតែប៉ុណ្ណោះ ។ ហើយកូនក្តីខ្លួនពេលកើតហេតុ នៅជាប់ចត្តាឡីស័ក ហើយកូនក្តីខ្លួនបានអនុញ្ញាតតែម្តងនោះទេ និងបានឆ្លើយសារភាព ទទួលកំហុសទាំងអស់ ហើយកូនក្តីខ្លួនប្រព្រឹត្តបទល្មើសតិចតួចបំផុត គឺតែមួយដង ហេតុនេះ សុំសម្រាលទោលដល់កូនក្តីខ្លួនទាំងពីរ តាមមាត្រា ៨៣,៨៤ នៃក្រមព្រហ្មទណ្ឌ។

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនពិតជាបានទទួលប្រាក់មែន ហើយកូនក្តីខ្លួនទទួលបាន លុយពីអ្នកបើកម៉ូតូ ហើយអង្គហេតុកើតឡើងនៅខែបី ហើយអង្គហេតុដែលតំណាងអយ្យការចោទប្រកាន់នោះនៅ ថ្ងៃមេសា ឯនោះ ។ ហើយកូនក្តីខ្លួនទទួលប្រាក់តែ ៧លានដុងទេ (បើគិតជាលុយដុល្លារ ២ ទៅ៣រយដុល្លារទេ) យ៉ាង ហោចណាស់កូនក្តីខ្លួនឃើញម៉ូតូបើកកាត់ គេយកលុយមកឱ្យក៏យកទៀត ហើយព្យសនកម្មតិចតួចបំផុត កូនក្តីខ្លួន សារភាពទទួលប្រាក់គេមែន ដូចនេះស្នើសុំតុលាការលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួន ដោយកូនក្តីខ្លួនប្រព្រឹត្តលើក ដំបូង។

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនឈ្មោះ [redacted] ចាន់នី ទទួលប្រាក់ពីអ្នកដឹកឈើ ឆ្លងកាត់ផ្លូវក្រវាត់ព្រំដែនដែលកងវិស្វកម្មកំពុងធ្វើ សម្រាប់ទិញបាយហូប ហើយកូនក្តីខ្លួនមិនបានសួរនាំនោះទេ ហើយកូនក្តីខ្លួនមិនបាននៅកន្លែងកើតហេតុនោះទេ ហេតុដូច្នេះស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួន មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

- ជនជាប់ចោទឈ្មោះ [redacted] ណារ៉ែ សំណូមពរឱ្យតុលាការលើកលែងទោស ទទួលស្គាល់កំហុសហើយ ខ្លួនពុំ មានចំណេះដឹងជ្រៅជ្រះទេ ហើយកន្លែងធ្វើការខ្លួនមានការខ្វះខាតបានទទួលប្រាក់បន្តិចបន្តួចយកមកធ្វើកន្លែងធ្វើ ការងារ ដូចជាទិញសម្ភារៈធ្វើការ ជាដើម ។

-ជនជាប់ចោទឈ្មោះ [redacted] សុផល សំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ ខ្លួនដឹងកំហុសហើយ

-ជនជាប់ចោទឈ្មោះ [redacted] ភារ័ត្ន សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសផង ដែលខ្លួនទទួលប្រាក់ ពីគេ ខ្លួនដឹងកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] សុខឡេង សំណូមពរសុំឱ្យតុលាការដោះលែងខ្លួនទៅផ្ទះវិញ ខ្លួនពុំបានប្រព្រឹត្តដូច ការចោទប្រកាន់ទេ។

-ជនជាប់ចោទឈ្មោះ [redacted] ចន្ថារី សំណូមពរសុំតុលាការ លើកលែងទោស ខ្លួនដឹងកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ញៀក សំណូមពរតុលាការ លើកលែងទោស ខ្លួនដឹងកំហុសហើយ ។



Scanned with CamScanner

- កំណត់ហេតុ ស្តីពីការចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ រួមមាន៖ ឈើមូលប្រភេទលេខ១ (ស្រឡៅ-សុក្រម)ចំនួន១៤៧កំណាត់,ឈើអារប្រភេទលេខ១ (ស្រឡៅ-សុក្រម) ចំនួន ១០៥កំណាត់, ត្រាក់ទ័រ ចំនួន ០២គ្រឿង, ម៉ូតូ (មិនស្គាល់ម៉ាក) ចំនួន ០២គ្រឿង និងរណាយន្ត០៣៨ ចំនួន ០១ គ្រឿង ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

- ក្រោយពីបានពិនិត្យលើភស្តុតាង

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

- ក្រោយពីពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការសាលាដំបូងខេត្តមណ្ឌលគិរី
## យល់ឃើញថា

ពិតជាមានអង្គហេតុកើតឡើងកាលពីអំឡុងខែឧសភា ខែមិថុនា ឆ្នាំ២០២១ នៅចំណុចអូរហ៊ិច ក្នុងភូមិអូរអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី មានករណីបទល្មើសធនធានធម្មជាតិ គឺការនាំចេញផល អនុផលព្រៃឈើ ដែលគ្មានអាជ្ញាប័ណ្ណ ករណីធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតផ្ទាល់ឬដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ និងករណីចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយលបលាក់បានកើតឡើង ប្រព្រឹត្តដោយជនជាប់ចោទ ជាជនជាតិវៀតណាម និងជនជាតិខ្មែរ ពិតប្រាកដមែន ។

- ជនជាប់ចោទឈ្មោះ [redacted] **ណារ៉ៃ** បានឆ្លើយសារភាពថា៖ កាលពីខែមេសា ឆ្នាំ២០២១ មានកូនចៅឈ្មោះ [redacted] ញ៉ែក បានមកឆ្លងយោបល់ថា សុំឱ្យវៀតណាមចូលដឹកឈើមួយយប់ ហើយខ្លួនបានអនុញ្ញាតឱ្យដឹងពិតប្រាកដមែន ដែលជាថ្នូរយកប្រាក់ពីជនជាតិវៀតណាមចំនួន ៦៥លានដុង ហើយឈ្មោះ [redacted] ញ៉ែក បានយកលុយឱ្យខ្លួនចំនួន ៦៥លានដុង ប្រហែល២ពាន់ដុល្លារ នេះសញ្ញាក់ឱ្យឃើញថាឈ្មោះ [redacted] ណារ៉ៃ មានចេតនាប្រព្រឹត្តបទល្មើស ហើយព្រមទទួលកំហុសរបស់ខ្លួនដែលប្រព្រឹត្តបទល្មើស ស្របតាមមាត្រា២៤នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] **ចន្ធារី** បានឆ្លើយសារភាពថា៖ ខ្លួនពិតបានទទួលប្រាក់ចំនួន ៤០លានដុង ពីឈ្មោះ [redacted] ញ៉ែក ជាការឱ្យជនជាតិវៀតណាមដឹកឈើចេញពីទឹកដីខ្មែរចូលទៅប្រទេសវៀតណាម ប្រាកដមែន ហើយប្រាក់ទាំងនោះខ្លួនមកយមកបែងចែក ដោយទិញសម្ភារៈដាក់កន្លែងធ្វើការអស់ចំនួន ១០លានដុង និងចែកឱ្យកូនចៅម្នាក់១ចំនួន ២លានដុង ។ នេះសញ្ញាក់ឱ្យឃើញថាឈ្មោះ [redacted] ចន្ធារី មានចេតនាប្រព្រឹត្តបទល្មើស ហើយព្រមទទួលកំហុសរបស់ខ្លួនដែលប្រព្រឹត្តបទល្មើស ស្របតាមមាត្រា២៤នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] **ញ៉ែក** បានឆ្លើយសារភាពថា៖ ក្នុងអំឡុងចុងខែមីនា ឆ្នាំ២០២១ ជនជាតិវៀតណាមឈ្មោះ ប៊ិច បានមកទំនាក់ទំនងខ្លួននៅប៉ុស្តិ៍អូរហ៊ិច សុំចេញឈើតែមួយយប់ទេ ដោយឱ្យតម្លៃចំនួន ១២០ លានដុង

ខ្លួនក៏បានទូរស័ព្ទទៅមេ ([redacted] ណារ៉ៃ) គាត់ក៏បានឯកភាព ។ ខ្លួនក៏បានឱ្យជនជាតិវៀតណាមចូលកាប់ឈើ និងបានទទួលប្រាក់ពីឈ្មោះ ប៊ិច ចំនួន ១២០ លានដុង ដោយផ្ទាល់ ហើយយកប្រាក់នោះមកចែកគ្នានៅប៉ុស្តិ៍អូរហ៊ុច ដោយចែកគ្នាចំនួនបីនាក់ គឺឈ្មោះ [redacted] ចន្ធារី បានចំនួន ៤០លានដុង មេបាន ៦៥លានដុង និងខ្លួនទទួលបាន១៥លានដុង ពិតប្រាកដមែន នេះសញ្ញាក់ឱ្យឃើញថាឈ្មោះ [redacted] ញ៉ែក មានចេតនាប្រព្រឹត្តបទល្មើស ហើយព្រមទទួលកំហុសរបស់ខ្លួនដែលប្រព្រឹត្តបទល្មើស ស្របតាមមាត្រា២៤នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] **ភារ័ត្ន** បានឆ្លើយសារភាពថា៖ នៅថ្ងៃកើតហេតុជនជាតិវៀតណាមឈ្មោះ ប៊ិច មកសួរនាំខ្លួន សុំឈើចេញ ហើយខ្លួនថា ខាងឃោធាអនុញ្ញាត ឬនៅ គាត់ថាព្រមហើយ ខ្លួនក៏អនុញ្ញាត ។ ខ្លួនបានទទួលប្រាក់ពីជនជាតិវៀតណាមចំនួន ១០០លានដុង ហើយចែកឱ្យរងចំនួនពីរនាក់ដោយម្នាក់ៗបាន ២០លានដុង ពិតប្រាកដមែន នេះសញ្ញាក់ឱ្យឃើញថាឈ្មោះ[redacted] ភារ័ត្ន មានចេតនាប្រព្រឹត្តបទល្មើស ហើយព្រមទទួលកំហុសរបស់ខ្លួនដែលប្រព្រឹត្តបទល្មើស ស្របតាមមាត្រា២៤នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ[redacted] **វណ្ណៈ** ហៅ **សុផល** បានឆ្លើយថា៖ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឈ្មោះ [redacted] ភារ័ត្ន ដែលជានាយប៉ុស្តិ៍បានប្រគល់ប្រាក់ឱ្យខ្លួនចំនួន ៤០លានដុង ចែកគ្នាជាមួយឈ្មោះ [redacted] សុខឡេង ចំនួន ២០ លានដុង ដែលជានាយរងប៉ុស្តិ៍ដូចគ្នា ពិតប្រាកដមែន គប្បីតុលាការពិចារណា ។

-ជនជាប់ចោទឈ្មោះ [redacted] **ចាន់ឌី** បានឆ្លើយថា៖ ខ្លួនពិតជាបានទទួលប្រាក់ចំនួន ៧លានដុង ហើយបានចែកឱ្យឈ្មោះ [redacted] សុផល ចំនួន ៤លានដុង ដែលជាថ្នូរនឹងការចាប់ម៉ូតូដឹកឈើចំនួនពីរគ្រឿងចេញពីទឹកដីខ្មែរចូលទៅប្រទេសវៀតណាម កាលពីចុងខែមីនា ឆ្នាំ២០២១ ប្រាកដមែន គប្បីតុលាការពិចារណា ។

-ជនជាប់ចោទឈ្មោះ[redacted] **សុខឡេង** ហៅ **មាប់** បានឆ្លើយថា៖ ខ្លួនជានាយរងប៉ុស្តិ៍នគរបាលព្រំដែនគោកអូរហ៊ុច ហើយខ្លួនពុំបានអនុញ្ញាតឱ្យជនជាតិវៀតណាមចូលមកកាប់ឈើនោះទេ ខ្លួនមិនដែលបានទទួលប្រាក់នោះទេ គឺខ្លួនមកនៅផ្ទះតាំងពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ គេរៀបចំប៉ុស្តិ៍ រហូតដល់ថ្ងៃទី១៦ មុនកើតហេតុ ខ្លួននៅធ្វើចត្តាឡីស័កចំពោះខែបួន ខែប្រាំ ខ្លួនទៅកន្លែងយូៗម្តង ព្រោះខ្លួនមានជម្ងឺទឹកនោមផ្អែម លើសឈាម ត្រឡប់មកផ្ទះរហូត ។ ខ្លួនសូមបញ្ជាក់ថា ខ្លួនពុំបានទទួលលុយទេ ព្រោះខ្លួនឈឺច្រើន ពុំដែលបាននៅកន្លែងជាប់លាប់ទេ ។ ហើយខ្លួនក៏មានលិខិតបញ្ជាក់ពីពេទ្យពីជំងឺស្ថានភាពជំងឺរបស់ខ្លួនដែរ។ ប៉ុន្តែតាមចម្លើយរបស់ឈ្មោះ [redacted] ភារ័ត្ន បានបញ្ជាក់ប្រាប់ថា ឱ្យប្រាក់ចំនួន៤០លានដុងទៅឱ្យឈ្មោះ [redacted] វណ្ណៈ ដើម្បីចែកគ្នាជាមួយឈ្មោះ [redacted] សុខឡេង ម្នាក់២០លានដុង ហើយចម្លើយឈ្មោះ [redacted] វណ្ណៈ ក៏បានបញ្ជាក់ប្រាប់ផងដែរថា យកប្រាក់ចំនួន ២០លានដុង ឱ្យឈ្មោះ [redacted] សុខឡេង ប៉ុស្តិ៍ ហើយគាត់ក៏បានបញ្ជាក់ប្រាប់ទៀតថា ក្រោយពីលោក [redacted] សុខឡេង ទទួលបានប្រាក់២០លានដុង រួចភ្លាមបានចេញមកផ្ទះតែម្តង ។ នេះសបញ្ជាក់ឱ្យឃើញថា ឈ្មោះ [redacted] សុខឡេង ទទួលប្រាក់២០លានដុង ពិតប្រាកដមែន គប្បីតុលាការពិចារណា ។

-ជនជាប់ចោទឈ្មោះ [redacted] **សុផល** បានឆ្លើយថា៖ ខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] ចាន់ឌី ចំនួន ៥លានដុង ជាថ្នូរក្នុងការឱ្យជនជាតិវៀតណាមចូលមកដឹកឈើពីទឹកដីខ្មែរចូលទៅប្រទេសវៀតណាម ពិតប្រាកដមែន គប្បីតុលាការពិចារណា ។

- សាក្សីឈ្មោះ [redacted] **សុត្ថា** បានឆ្លើយថា៖ កាលពីខែមិថុនា ឆ្នាំ២០២១ ក្រុមការងារចុះប្រតិបត្តិការណ៍នៅជិតស្នាក់ការអូរហ៊ុច ឃើញមានអាត្រាក់ទ័រមួយគ្រឿង អូសឈើពីទឹកដីខ្មែរទៅចូលទឹកដីវៀតណាម ដែលដឹកនាំដោយលោកព្រះរាជអាជ្ញារង ចាប់បានត្រង់សឺន័រ និងឈើជាច្រើនដុំ ហើយឈើមួយចំនួនបានយកមករក្សាទុកនៅស្នាក់ការបរិស្ថានខ្លះ និងមួយចំនួនដែលនៅសល់នៅកន្លែងកើតហេតុ។ ចំណែកឯកជនល្មើសជាជនជាតិវៀតណាមបានរត់គេចខ្លួនបាត់អស់ដោយសារមានអ្នកបើកឡានមកបិទផ្លូវក្រុមការងារទៅមិនរួច។ បន្ទាប់មកក៏បានធ្វើការស៊ើបអង្កេត ហើយបានកោះហៅអ្នកពាក់ព័ន្ធមកសួរនាំ រួចកសាងសំណុំរឿងមកតំណាងអយ្យការចាត់ការបន្ត។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលក្នុងសវនាការ ឃើញថាជនជាប់ចោទទាំង ០៨នាក់ ពិតជាបានទទួលប្រាក់ពីជនជនជាតិវៀតណាម ដោយផ្ទាល់ និងប្រយោល ដើម្បីឱ្យដឹកឈើចេញពីទឹកដីខ្មែរ ទៅប្រទេសវៀតណាម ពិតប្រាកដមែន ។ ហេតុនេះតំណាងអយ្យការប្តឹងចោទប្រកាន់ជនជាប់ចោទពី បទ **ធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ និងដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ** តាមបញ្ញត្តិមាត្រា ១០០ នៃច្បាប់ស្តីព្រៃឈើ ប្រព្រឹត្តនៅត្រង់ចំណុចអូរហ៊ុច ស្ថិតនៅភូមិអូរអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២១ ។ ប៉ុន្តែចំពោះចម្លើយដែលឈ្មោះ [redacted] សុខឡេង បានឆ្លើយដោះសារ ពុំទទួលប្រាក់នោះទេ ដើម្បីរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌ តំណាងអយ្យការពុំជឿជាក់នោះទេ ព្រោះជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានយកលុយចំនួន ២០លានដុងឱ្យតាមបញ្ជាមេប៉ុស្តិ៍ឈ្មោះ [redacted] ភារ័ត្ន ដូចច្នេះតំណាអយ្យការប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខឡេង តាមច្បាប់។

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនពិតជាបានទទួលប្រាក់ពិតមែន ហើយឈ្មោះ [redacted] ណារ៉ៃ បានទទួល៦៥លានដុង និងឈ្មោះ [redacted] ចន្ទារី ទទួលបាន ៤០លានដុង គឺទទួលយកមកដើម្បីកសាងស្នាក់ការធ្វើការតែប៉ុណ្ណោះ ។ ហើយកូនក្តីខ្លួនពេលកើតហេតុ នៅជាប់ចត្តាឡីស័ក ហើយកូនក្តីខ្លួនបានអនុញ្ញាតតែម្តងនោះទេ និងបានឆ្លើយសារភាព ទទួលកំហុសទាំងអស់ ហើយកូនក្តីខ្លួនប្រព្រឹត្តបទល្មើសតិចតួចបំផុត គឺតែមួយដង ហេតុនេះសុំសម្រាលទោលដល់កូនក្តីខ្លួនទាំងពីរ តាមមាត្រា ៩៣,៩៤ នៃក្រមព្រហ្មទណ្ឌ។

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនពិតជាបានទទួលប្រាក់មែន ហើយកូនក្តីខ្លួនទទួលបានលុយពីអ្នកបើកម៉ូតូ ហើយអង្គហេតុកើតឡើងនៅខែបី ហើយអង្គហេតុដែលតំណាងអយ្យការចោទប្រកាន់នោះនៅថ្ងៃមេសា ឯនោះ ។ ហើយកូនក្តីខ្លួនទទួលប្រាក់តែ ៧លានដុងទេ (បើគិតជាលុយដុល្លារ ២ ទៅ៣រយដុល្លារទេ) យ៉ាងហោចណាស់កូនក្តីខ្លួនឃើញម៉ូតូបើកកាត់ គេយកលុយមកឱ្យក៏យកទៀត ហើយព្យសនកម្មតិចតួចបំផុត កូនក្តីខ្លួនសារភាពទទួលប្រាក់គេមែន ដូចនេះស្នើសុំតុលាការលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួន ដោយកូនក្តីខ្លួនប្រព្រឹត្តលើកដំបូង។



Scanned with CamScanner

-មេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនឈ្មោះ [redacted] ចាន់ឌី ទទួលប្រាក់ពីអ្នកដឹកឈើឆ្លងកាត់ផ្លូវក្រវាត់ព្រំដែនដែលកងវិស្វកម្មកំពុងធ្វើ សម្រាប់ទិញបាយហូប ហើយកូនក្ដីខ្លួនមិនបានសួរនាំនោះទេ ហើយកូនក្ដីខ្លួនមិនបាននៅកន្លែងកើតហេតុនោះទេ ហេតុដូច្នេះស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់ដល់កូនក្ដីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ តុលាការមិនយល់ស្របនោះទេ ដោយជនជាប់ចោទរូបនេះ បានទទួលប្រាក់ ហើយមិនបានប្ដឹងបរិហារអំពីបទល្មើស បែរជាអនុញ្ញាតឱ្យជនល្មើសដឹកឈើចេញពីទឹកដីខ្មែរឆ្លងកាត់ទៅប្រទេសវៀតណាមទៅវិញ គប្បីតុលាការពិចារណា ។

-សម្ដីចុងក្រោយរបស់ជនជាប់ចោទទាំង ០៨នាក់ សុំឱ្យតុលាការបន្ធូរបន្ថយទោស ពួកខ្លួនបានដឹងនូវកំហុស សន្យាថាឈប់ប្រព្រឹត្តតទៅទៀតហើយ ។

-ជនជាប់ចោទទាំងប្រាំបីនាក់ជានីតិជនមានសញ្ញាណបញ្ជាក់ថា មិនកើតវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើរបស់ខ្លួន ដែលបានប្រព្រឹត្តបទល្មើស ។

-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើឈ្មោះ [redacted] ណាខៃ, ឈ្មោះ [redacted] ចន្ថារី, ឈ្មោះ [redacted] ញៀក, ឈ្មោះ [redacted] ភារ័ត្ន, ឈ្មោះ [redacted] វណ្ណៈ ហៅ សុផល, ឈ្មោះ [redacted] ចាន់ឌី, ឈ្មោះ [redacted] សុខឡេង ហៅ ម៉ាប់ និងឈ្មោះ [redacted] សុផល ពីបទ: **ធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្ដល់ការអនុញ្ញាតដោយផ្ទាល់ និងដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ** តាមបញ្ញត្តិមាត្រា ១០០ នៃច្បាប់ស្ដីព្រៃឈើ ប្រព្រឹត្តនៅត្រង់ចំណុច អូរហ៊ុច ស្ថិតនៅភូមិអូរអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២១។

- កំណត់ហេតុ ស្ដីពីការចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ រួមមាន៖ ឈើមូលប្រភេទលេខ១ (ស្រឡៅ-សុក្រម) ចំនួន ១៤៧កំណាត់,ឈើអារប្រភេទលេខ១ (ស្រឡៅ-សុក្រម) ចំនួន ១០៥កំណាត់, ត្រាក់ទ័រ ចំនួន ០២គ្រឿង, ម៉ូតូ (មិនស្គាល់ម៉ាក) ចំនួន ០២គ្រឿង និងរណារយន្ត០៣៨ ចំនួន ០១គ្រឿង គប្បីរឹបអូសជាសម្បត្តិរដ្ឋ។

-ជនជាប់ចោទទាំង ០៨នាក់ ទើបតែប្រព្រឹត្តបទល្មើសលើកដំបូង គប្បីតុលាការពិចារណា ។

- ជនជាប់ចោទឈ្មោះ [redacted] សុខឡេង មានជំងឺប្រចាំកាយ ដូចជាទឹកនោមផ្អែម រលាកថ្លើមប្រភេទបេ និងរលាកក្រពះ ជាទំងន់ ដែលមានលិខិតបញ្ជាក់ពីបញ្ហាសុខភាពរបស់គាត់ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២១ របស់ពន្ធនាគារខេត្តមណ្ឌលគិរី និងលិខិតបញ្ជាក់ពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៩ និងលិខិតបញ្ជាក់ពិសោធន៍វេជ្ជសាស្ត្រ [redacted] ចាន់ថាត ផ្សារកែវសីមា ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១៩ គប្បីតុលាការពិចារណា ។

## ហេតុដូច្នេះសាលាដំបូងខេត្តមណ្ឌលគិរី
## វិនិច្ឆ័យសេចក្ដី

១/ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ណាខៃ,ឈ្មោះ [redacted] ចន្ថារី,ឈ្មោះ [redacted] ញៀក និងឈ្មោះ [redacted] ភារ័ត្ន ដាក់ពន្ធនាគារក្នុងម្នាក់ៗ ចំនួន ០២ (ពីរ)ឆ្នាំ ពីបទ: **ធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្ដល់ការអនុញ្ញាត**



Scanned with CamScanner

**ដោយផ្ទាល់ និងដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ** ប្រព្រឹត្តនៅត្រង់ចំណុច អូរហ៊ុច ស្ថិតនៅភូមិអូរអាម ឃុំស្រែខ្ទម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២១ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១០០ នៃច្បាប់ស្តីពីព្រៃឈើ ។

២/ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ហៅ សុផល,ឈ្មោះ [redacted] ចាន់ឌី និងឈ្មោះ [redacted] សុផល ដាក់ពន្ធនាគារក្នុងម្នាក់ៗ ចំនួន ០១(មួយ)ឆ្នាំ តែទោសអនុវត្តក្នុងពន្ធនាគារម្នាក់ៗចំនួន ១០(ដប់)ខែ តែទោសពីនេះត្រូវព្យួរ ពីបទៈ **ធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ និងដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ** ប្រព្រឹត្តនៅត្រង់ចំណុច អូរហ៊ុច ស្ថិតនៅភូមិអូរអាម ឃុំស្រែខ្ទម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២១ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១០០ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

៣/ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខឡេង ហៅ ម៉ាប់ ដាក់ពន្ធនាគារចំនួន ០១ (មួយ)ឆ្នាំ តែទោសអនុវត្តចំនួន ០៨ (ដប់) ខែ ពីបទៈ **ធ្វើសកម្មភាពទាំងឡាយណាដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ និងដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ** ប្រព្រឹត្តនៅត្រង់ចំណុចអូរហ៊ុច ស្ថិតនៅភូមិអូរអាម ឃុំស្រែខ្ទម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី កាលពីអំឡុងខែមិថុនា ឆ្នាំ២០២១ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១០០ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

៤/រឹបអូសវត្ថុតាង៖ ឈើមូលប្រភេទលេខ១ (ស្រឡៅ-សុក្រម)ចំនួន ១៤៧កំណាត់,ឈើអារប្រភេទលេខ១ (ស្រឡៅ-សុក្រម)ចំនួន ១០៥កំណាត់,ត្រាក់ទ័រ ចំនួន ០២គ្រឿង, ម៉ូតូ (មិនស្គាល់ម៉ាក) ចំនួន ០២គ្រឿង និងរណារយន្ត ០៣៨ ចំនួន ០១គ្រឿង ជាទ្រព្យសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជំរះនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ណារ៉ែ,ឈ្មោះ [redacted] ចន្ធារី,ឈ្មោះ [redacted] ញ៉ែក,ឈ្មោះ [redacted] ភារ័ត្ន,ឈ្មោះ [redacted] វណ្ណៈ ហៅ សុផល,ឈ្មោះ [redacted] ចាន់ឌី,ឈ្មោះ [redacted] សុខឡេង ហៅ ម៉ាប់ និងឈ្មោះ [redacted] សុផល ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៩រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ២៥៦៥

មណ្ឌលគិរី.ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

Scanned with CamScanner